29 Suramarith Boulevard
Chaktomuk, Daun Penh
Phnom Penh, Cambodia
Tel: (+855) 23 215 805/6
Fax: (+855) 23 215 807
E-mail: adbcarm@adb.org

**ADB News Release**

ASIAN DEVELOPMENT BANK

# ក្រុមហ៊ុនតូចៗនៅកម្ពុជា នឹងកាន់តែមានលទ្ធភាពច្រើនជាងមុន ក្នុងការទទួលបានកម្ចីពីធនាគារ

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា (២៨ ឧសភា ២០១៤) -** ថ្ងៃនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានចុះហត្ថលេខាលើកម្ចី ក្នុងទឹកប្រាក់ចំនួន ៧៥ លានដុល្លារ ជាមួយនឹងធនាគារអេស៊ីលីដា ដែលជាធនាគារធំជាងគេមួយនៅក្នុងប្រទេសកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនូវតម្រូវការកម្ចីរបស់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម (MSMEs) នៅក្នុងប្រទេសនេះ។

លោកស្រី Christine Engstrom ប្រធាននាយកដ្ឋានប្រតិបត្តិការវិស័យឯកជននៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលចុះ ហត្ថលេខា ក្នុងនាមតំណាងឱ្យធនាគារអភិវឌ្ឍន៍អាស៊ី មានប្រសាសន៍ថា “ជំនួយនេះនឹងលើកកម្ពស់លទ្ធភាពរបស់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ក្នុងការទទួលបានកម្ចីរយៈពេលវែង ដែលមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតចំណូល និងការងារ នៅតាមតំបន់ជនបទ ដែលមានប្រជាពលរដ្ឋកម្ពុជាក្រីក្រប្រមាណជា ៩០% រស់នៅ។”

សេវាហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា ស្ថិតនៅក្នុងចំណោមសេវា ដែលមានកម្រិតទាបជាងគេ នៅអាស៊ី និងប៉ាស៊ីហ្វិចនេះ។ ខណៈពេលដែលសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម មាន ៩៩% នៃក្រុមហ៊ុនឯកជន និងផ្តល់ការងារ ៧៣% ក្នុងចំណោមការងារទាំងអស់ នៅក្នុងប្រទេសនេះ សហគ្រាសទាំងនេះមានលទ្ធភាពតិចតួចបំផុត ក្នុងការទទួលបានកម្ចីពីធនាគារ។ បើតាមធនាគារជាតិរបស់ប្រទេសនេះ សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ចំនួន ៨៤% ទទួលបានកម្ចីពីវិស័យហិរញ្ញវត្ថុក្រៅប្រព័ន្ធ ដែលការប្រាក់អាចមានកម្រិតខ្ពស់រហូត ដល់ ១០% ក្នុងមួយខែ។

ធនាគារអេស៊ីលីដា ដែលមានបណ្តាញសាខាយ៉ាងច្រើន នៅតាមតំបន់ជនបទ នឹងប្រើប្រាស់កម្ចីនេះ ដើម្បីពង្រីកមូលដ្ឋានកម្ចីរបស់ខ្លួន ក៏ដូចជាពង្រីកសេវារបស់ខ្លួន ដល់សហគមន៍ ដែលមិនបានទទួលសេវាគ្រប់

សំណួរសម្រាប់អ្នកសារព័ត៌មាន
Karen Lane
(632) 632 6138
(63) 920 938 6487
អ៊ីមេល÷klane@adb.org

គ្រាន់ រាប់បញ្ចូលទាំងការប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធទូរស័ព្ទចល័តរបស់ខ្លួនប្រកបដោយជោគជ័យផងដែរ។ ធនាគារអេស៊ីលីដា ធ្លាប់ជាអង្គការមិនមែនរដ្ឋាភិបាល ចាប់តាំងពីឆ្នាំ ១៩៩២ មក។

ធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់នូវកម្ចីរយៈពេលវែងប្រកបដោយស្ថិរភាពមួយ ដែលបច្ចុប្បន្ននេះ មិនអាចប្រមូលបានពីទីផ្សារក្នុងប្រទេសបាន ហើយដែលជាកម្ចីចាំបាច់ ដើម្បីជួយឱ្យធនាគារនេះអាចដោះស្រាយភាពខុសគ្នានៃថ្ងៃដល់ការកំណត់រវាងប្រាក់បញ្ញើ និងកម្ចីនៅធនាគារ។

ជំនួយនេះក៏នឹងផ្តល់លទ្ធភាពឱ្យធនាគារអភិវឌ្ឍន៍អាស៊ី អាចពង្រឹងទំនាក់ទំនងរបស់ខ្លួនឱ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត ជាមួយនឹងធនាគារនេះ ដែលមានវត្តមានផងដែរ នៅក្នុងសាធារណរដ្ឋប្រជាមានិតឡាវ និងមីយ៉ាន់ម៉ាផងដែរ ក៏ដូចជាពង្រឹងសក្តានុពលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការជួយលើកកម្ពស់ការទទួលបានសេវាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ នៅតាមទីផ្សារដែលជួបប្រទះការលំបាកទាំងនេះ។

មានមូលដ្ឋាននៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រ នៅអាស៊ី និងប៉ាស៊ីហ្វិកតាមរយៈកំណើនសេដ្ឋកិច្ចដើម្បីទាំងអស់គ្នា កំណើនដែលធានានិរន្តរភាពបរិស្ថាន និងសមាហរណកម្មតំបន់។ បង្កើតឡើងនៅក្នុងឆ្នាំ ១៩៦៦ ធនាគារនេះគឺជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ប្រទេស ដែលក្នុងនោះមាន ៤៨ ប្រទេសមកពីតំបន់នេះ។ នៅក្នុងឆ្នាំ ២០១៣ ជំនួយដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ីសរុបមានចំនួន ២១ ពាន់លានដុល្លារ បូករួមទាំងសហប្រទានចំនួន ៦,៦ ពាន់លានដុល្លារផង។

*****